# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តព្រះសីហនុ**
សំណុំរឿងព្រហ្មទណ្ឌលេខៈ ៩៤៦
ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៩
សាលក្រមលេខៈ **២៧៧/៣៧** (ក)
ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២០
ថ្ងៃអង្គារ ៧កើត ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស២៥៦៣

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តព្រះសីហនុ

បានឃើញ ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ។

បានបើកសវនាការជាសាធារណៈ នៅសាលាដំបូងខេត្តព្រះសីហនុនៅថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២០ វេលាម៉ោងប្រាំបី និងសាមសិបនាទីព្រឹក ដែលមានសមាសភាពចូលរួម ៖

## ចៅក្រមជំនុំជម្រះ

-លោក [redacted] ជាចៅក្រមជំនុំជម្រះ

## តំណាងអយ្យការ

-លោក [redacted] ជាព្រះរាជអាជ្ញារង

## ក្រឡាបញ្ជីសវនាការ

-លោក [redacted] ជាក្រឡាបញ្ជីសវនាការ

**ដើម្បីជំនុំជម្រះ ៖**

សំណុំរឿងព្រហ្មទណ្ឌលេខ ៩៤៦ ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៩ ដែលមានជនជាប់ចោទ ៖

ឈ្មោះ [redacted] HAO ភេទប្រុស អាយុ ៣៣ឆ្នាំ ជនជាតិចិន មុខរបរ មិនពិតប្រាកដ កម្រិតវប្បធម៌មហាវិទ្យាល័យ ទីកន្លែងកំណើត [redacted] ប្រទេសចិន ទីលំនៅមុនពេលឃុំខ្លួនភូមិ២ សង្កាត់លេខ២ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ នៅលីវ ឪពុកឈ្មោះ [redacted] HAO PAN (រ) ម្តាយឈ្មោះ [redacted] FANG (រ) ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការគ្មាន ។



Scanned with CamScanner

ត្រូវបានឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនបណ្ដោះអាសន្នលេខ ៤០៤៨ ត.ព.ជ/១៩ ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៩ និងឃុំខ្លួនបន្តតាមដីកាបង្គាប់ឱ្យឃុំខ្លួនបណ្ដោះអាសន្នបន្ត លេខ ៦៤៩៣ តពជ/១៩ របស់សាលាដំបូងខេត្តព្រះសីហនុ ។

ត្រូវបានចោទប្រកាន់ពីបទ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ និងមាត្រា ៤៨ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ប្រព្រឹត្តនៅចំណុចភូមិ៣ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៩ ។

**<u>មានមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ៖</u>**

លោកមេធាវី [redacted] មានការិយាល័យផ្ទះលេខ៧១ ផ្លូវបុរីកម្មករ ក្រុមទី១១ ភូមិ៣ សង្កាត់លេខ២ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ។

កញ្ញាមេធាវី [redacted] មានការិយាល័យផ្ទះលេខ៧១ ផ្លូវបុរីកម្មករ ក្រុមទី១១ ភូមិ៣ សង្កាត់លេខ២ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ។

**<u>អ្នកបកប្រែ៖</u>**

ឈ្មោះ [redacted] **គីមហុង** ភេទប្រុស មានអាសយដ្ឋាននៅក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ។

## ១.អង្គហេតុនៃបណ្ដឹងចោទប្រកាន់

កាលពីថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៩ ស្ថិតនៅចំណុចភូមិ៣ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កម្លាំងការិយាល័យប្រឆាំងគ្រឿងញៀនបានបង្ក្រាបករណីជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ដោយឃាត់ខ្លួនបានជនសង្ស័យចំនួន ០១នាក់ ឈ្មោះ [redacted] HAO ភេទប្រុស និងដកហូតបានម្សៅសថ្លាប្រភេទមេតំហ្វេតាមីនចំនួន ២៣កញ្ចប់ ទម្ងន់ ២៣,៣០ ក្រាម, ថ្នាំញៀនប្រភេទកេតាមីន (K) ចំនួន ០១កញ្ចប់ ទម្ងន់ ១២,៨៣ក្រាម និងថ្នាំញៀនប្រភេទ WY ចំនួន ១០គ្រាប់ទម្ងន់ ០.៩៨ ក្រាម និងជញ្ជីងថ្លឹងថ្នាំញៀន ។

-**បានឃើញ** ដីកាបញ្ជូនរឿងទៅជំនុំជម្រះលេខ ៧៩៣ ត.៧/២០ ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តព្រះសីហនុ ។

## ២. នាពេលសវនាការ

**២.១ ការស្ដាប់ចម្លើយរបស់ជនជាប់ចោទ:** *ជនជាប់ចោទឈ្មោះ* [redacted] *HAO បានឆ្លើយថា:* ខ្លួនចេះប្រើប្រាស់គ្រឿងញៀនប្រហែល ០៣ខែ ទៅ ០៤ខែហើយ ប៉ុន្តែខ្លួនមិនដែលជួញដូរគ្រឿងញៀននោះទេ ។ ខ្លួនបានធ្លាប់ទិញគ្រឿងញៀនចំនួន០២លើកមក ដោយលើកទី០១ទិញអស់ចំនួន ៥០០ដុល្លារអាមេរិក ទិញពីអ្នកបើកតុកតុក នៅមុខសណ្ឋាគារឃ្វីនកូ ឈ្មោះ អាយុន ជនជាតិខ្មែរ លើកទី០២ ទិញពីជនជាតិចិន ឈ្មោះ [redacted] ហ៊ាវ ចំនួន៥០០

ដុល្លារអាមេរិក នៅជិតគោពីរ ភូមិ៤ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ។ សមត្ថកិច្ចបានឃាត់រូបខ្លួននៅខាងក្រោយសណ្ឋាគារជីងប៉ី ព្រមទាំងបានដកហូតទូរស័ព្ទ, បារីមួយកញ្ចប់ និងកាតបន្ទប់ដេក តែមិនមានគ្រឿងញៀននៅជាប់នឹងរូបខ្លួនទេ គឺសមត្ថកិច្ចឆែកឆេរឃើញនៅក្នុងបន្ទប់ស្នាក់នៅរបស់ខ្លួន ។ សមត្ថកិច្ចបានដកហូតគ្រឿងញៀនចំនួន ០៣ប្រភេទ មានគ្រឿងញៀនប្រភេទ WY, គ្រឿងញៀនប្រភេទម្សៅ K, គ្រឿងញៀនICE ហៅម៉ាទឹកកក និងជញ្ជីងសម្រាប់ថ្លឹងមាសចំនួន ០១គ្រឿង ។ ចំពោះជញ្ជីងថ្លឹងជារបស់មិត្តភក្តិរបស់ខ្លួន ជញ្ជីងថ្លឹងនេះ គឺខ្លួន និងមិត្តភក្តិទុកសម្រាប់ថ្លឹងមាសពីអ្នកដែលចង់លក់នៅក្នុងកាស៊ីណូ ។

**២.២** *តុលាការបង្គាប់ឱ្យក្រឡាបញ្ជី អានអំណានចម្លើយរបស់សាក្សីដែលជាសមត្ថកិច្ចឈ្មោះ* [redacted] *រតនៈ នៅតំណាក់កាលចៅក្រមស៊ើបសួរដែលមានខ្លឹមសារថា:* កាលពីថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៩ វេលាម៉ោង០៥ និង ៣០នាទី នៅចំណុចក្រុមទី១៣ ភូមិ៣ សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កម្លាំងការិយាល័យនគរបាលប្រឆាំងគ្រឿងញៀន បានបង្ក្រាបករណីជួញដូរគ្រឿងញៀនមួយករណីដោយឃាត់ខ្លួនជនសង្ស័យចំនួន ០១នាក់ឈ្មោះ [redacted] HAO ភេទប្រុស អាយុ ៣៣ឆ្នាំជនជាតិចិន មុខរបរមិនពិតប្រាកដ មានទីលំនៅភូមិ២ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ដោយដកហូតបានម្សៅក្រាមពណ៌សថ្លា សង្ស័យជាសារធាតុញៀនប្រភេទមេតំហ្វេតាមីនទឹកកក (ICE) ចំនួន ២៣កញ្ចប់ (ធំ ០១កញ្ចប់) ម្សៅក្រាមពណ៌ស សង្ស័យជាសារធាតុញៀន ប្រភេទកេតាមីន (K) ចំនួន០១កញ្ចប់ ជញ្ជីងថ្លឹងថ្នាំចំនួន ០១គ្រឿង និងទូរស័ព្ទដៃចំនួន ០២គ្រឿង ។

**២.៣** *តុលាការបង្គាប់ឱ្យក្រឡាបញ្ជីអានកំណត់ហេតុចាប់យកវត្ថុតាង និងសម្ភារៈលេខ: ៥០៥ កណហ/១៩ ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០២០*[1] *របស់ការិយាល័យនគរបាលប្រឆាំងគ្រឿងញៀន នៃស្នងការនគរបាលខេត្តព្រះសីហនុ ត្រង់ផ្នែកវត្ថុតាង និងសម្ភារៈចាប់យកដែលមានខ្លឹមសារថា:* ម្សៅក្រាមពណ៌ស ចំនួន២៣កញ្ចប់ សង្ស័យជាសារធាតុញៀន, ម្សៅសថ្លាចំនួន០១កញ្ចប់សង្ស័យជាសារធាតុញៀនកេតាមីន, ថ្នាំគ្រាប់WY ចំនួន១០គ្រាប់ ,ទូរសព្ទដៃចំនួន០២គ្រឿង (ម៉ាកម៉ីពណ៌ខៀវ០១គ្រឿង, ពណ៌ទឹកមាស០១គ្រឿង) និងជញ្ជីងចំនួន០១គ្រឿង ។

**២.៤** *តុលាការបង្គាប់ឱ្យក្រឡាបញ្ជីអានលទ្ធផលកោសលវិច័យគ្រឿងញៀន លេខ:២១៥៧២/១៩ ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៩ របស់មន្ទីរពិសោធនៃអគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។*

---

[1] *កំណត់ហេតុចាប់យកវត្ថុតាង និងសម្ភារៈលេខ: ៥០៥ កណហ/១៩ ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៩ របស់ស្នងការនគរបាលខេត្តព្រះសីហនុ ។ (ឯកសារលេខ១៧/២) ។*



Scanned with CamScanner

២.៥ **ការស្តាប់សេចក្តីសន្និដ្ឋានចោទរបស់តំណាងអយ្យការ:** ការដកហូតគ្រឿងញៀនមានច្រើនប្រភេទ និងមានជញ្ជីងថ្លឹងចំនួន ០១គ្រឿង នេះបញ្ជាក់ឱ្យឃើញថា ជនជាប់ចោទពិតជាអ្នកជួញដូរគ្រឿងញៀនពិតប្រាកដមែន ដូច្នេះតំណាងអយ្យការសូមតម្កល់ការចោទប្រកាន់ទុកជាបានការ និងសូមឱ្យតុលាការផ្តន្ទាទោសជននេះតាមច្បាប់ ។

២.៦ **ការស្តាប់ការសន្និដ្ឋានចុងក្រោយរបស់មេធាវីជនជាប់ចោទ:** កូនក្តីខ្លួនបានសារភាពថាគ្រឿងញៀនទាំងនោះគឺសមត្ថកិច្ចបានដកហូតពីក្នុងបន្ទប់របស់គាត់មែន ប៉ុន្តែគាត់ទុកសម្រាប់ប្រើប្រាស់ប៉ុណ្ណោះ មិនមែនទុកលក់ទេ និងសូមឱ្យតុលាការជួយសម្រាលទោសឱ្យកូនក្តីខ្លួនផង ដោយយោងតាមមាត្រា ៩៣ នៃក្រមព្រហ្មទណ្ឌ ។

២.៧ **ការស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ:** សូមឱ្យតុលាការជួយបន្ធូរបន្ថយទោស ។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់អំនានចម្លើយរបស់សាក្សី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានចុងក្រោយរបស់មេធាវីជនជាប់ចោទ

-ក្រោយពីបានស្តាប់សម្តីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យកស្តុតាងនានាក្នុងសំណុំរឿង

-បានឃើញ កំណត់ហេតុជំនុំជម្រះចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តព្រះសីហនុ ។

## ៣.ផ្នែកសំអាងហេតុ

## ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់
## សាលាដំបូងខេត្តព្រះសីហនុ យល់ឃើញថា ៖

៣.១ តាមដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ: ៧៥៣ ត.៧/២០ ចុះថ្ងៃទី ២០ ខែកុម្ភៈ ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តព្រះសីហនុ [2] ចៅក្រមស៊ើបសួរបានសម្រេចប្តឹងចោទប្រកាន់លើឈ្មោះ [redacted] HAO ភេទប្រុស ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ និងមាត្រា ៤៨ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រព្រឹត្តនៅចំណុចភូមិ៣ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៩ ។

---

2 ដីកាបញ្ជូនរឿងទៅជំនុំជម្រះលេខ ៧៥៣ ត.៧/២០ ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តព្រះសីហនុ ។ (ឯកសារលេខ ២៩)



Scanned with CamScanner

៣.២ អំពើល្មើសដែលរងការចោទប្រកាន់ត្រូវបានប្រព្រឹត្តឡើងនៅថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៩ ដូច្នេះអំពើនេះត្រូវស្ថិតក្នុងវិសាលភាព នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៣.៣ តាមរបាយការណ៍លេខ ៥០៥ រ.ប.ក/១៩ ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៩[3] របស់ការិយាល័យនគរបាលប្រឆាំងគ្រឿងញៀន នៃស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ បានបញ្ជាក់ថា កាលពីថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៩ ស្ថិតនៅក្រុម១៣ ភូមិ៣ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កម្លាំងការិយាល័យប្រឆាំងគ្រឿងញៀន បានចុះបង្ក្រាបករណីជួញដូរគ្រឿងញៀន បាន ០១ករណី ដោយឃាត់ខ្លួនបានជនសង្ស័យចំនួន ០១នាក់ មានឈ្មោះ [redacted] HAO ភេទប្រុស អាយុ ៣៣ឆ្នាំ ជនជាតិចិន ព្រមទាំងបានដកហូតនូវវត្ថុតាងដែលសង្ស័យថាជាគ្រឿងញៀនមួយចំនួន និងជញ្ជីងសម្រាប់ថ្លឹងគ្រឿងញៀនផងដែរ ។

៣.៤ ផ្អែកតាមរបាយការណ៍លេខ ៥០៥ រ.ប.ក/១៩ ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៩ របស់ការិយាល័យនគរបាលប្រឆាំងគ្រឿងញៀន នៃស្នងការដ្ឋាននគរបាលខេត្ត ត្រង់ផ្នែកសេចក្តីសន្និដ្ឋាន បានបញ្ជាក់ផងដែរថាឈ្មោះ [redacted] HAO ពិតជាបានប្រព្រឹត្តបទល្មើស ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រាកដមែន ។

៣.៥ នាពេលសវនាការជនជាប់ចោទឈ្មោះ [redacted] HAO បានឆ្លើយបដិសេធថារូបគេមិនដែលជួញដូរគ្រឿងញៀននោះទេ ដោយរូបគេចេះតែប្រើប្រាស់ប៉ុណ្ណោះ ប៉ុន្តែចម្លើយដោះសារបែបនេះមិនអាចឱ្យតុលាការជឿជាក់បាននោះទេថា រូបគេពិតជាមិនបានប្រព្រឹត្តដូចការចោទប្រកាន់មែន ដោយហេតុថាបើផ្អែកលើសារធាតុញៀនដែលសមត្ថកិច្ច បានធ្វើការដកហូតពីបន្ទប់ដែលជននេះស្នាក់នៅមានចំនួនច្រើន ដែលចំនួននេះ គឺមិនស្ថិតនៅក្នុងរូបភាពនៃការទិញយកមកប្រើប្រាស់តែមួយមុខនោះទេ ម្យ៉ាងទៀតសមត្ថកិច្ចក៏បានធ្វើការដកហូតនូវជញ្ជីងសម្រាប់ថ្លឹងគ្រឿងញៀនទៀត ដែលនេះគឺបានរំលេចឱ្យឃើញកាន់តែច្បាស់ថាជនជាប់ចោទឈ្មោះ [redacted] HAO គឺមានជាប់ពាក់ព័ន្ធទៅនឹងការជួញដូរដោយខុសច្បាប់នូវសារធាតុញៀនប្រាកដមែន ។

៣.៦ សកម្មភាពទាក់ទងនឹងសារធាតុញៀន ត្រូវបានហាមឃាត់ដោយច្បាប់របស់ប្រទេសកម្ពុជា ដូច្នេះការដែលជនជាប់ចោទបានដឹងរួចហើយថា សកម្មភាពដែលខ្លួនបានធ្វើ គឺជាអំពើខុសច្បាប់ ប៉ុន្តែខ្លួននៅតែប្រព្រឹត្តនោះ គឺពិតជាស្តែងឱ្យឃើញ

---

[3] របាយការណ៍លេខ ៥០៥ រ.ប.ក/១៩ ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៩ របស់ស្នងការនគរបាលខេត្តព្រះសីហនុ។ (ឯកសារលេខ១/១៧)



Scanned with CamScanner

អំពី ចេតនាទុច្ចរិតពិតប្រាកដ របស់ជនជាប់ចោទក្នុងការប្រព្រឹត្តអំពើល្មើសដែលបានចោទប្រកាន់ ។

៣.៧ ក្នុងចំណោមវត្ថុតាងដែលសមត្ថកិច្ចឆែកឆេរកឃើញ និងចាប់យកមកនេះ ឃើញថាវត្ថុតាងទាំងនោះត្រូវបានមន្ទីរពិសោធន៍នៃអគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ផ្តល់លទ្ធផលនៃការធ្វើកោសលវិច័យចំពោះគ្រឿងញៀន ដែលមានចំនួន ០៣សំណាក គឺជាគ្រឿងញៀនប្រភេទ **កេតាមីន**, គ្រឿងញៀនប្រភេទ **មេតំហ្វេតាមីន** និងជាគ្រឿងញៀនប្រភេទ **មេតំហ្វេតាមីន** តាម**លិខិតលេខ ២១៥៧២/១៩** ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៩ ។

៣.៨ តាមលិខិតលេខ **២១៥៧២/១៩** ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៩[4] របស់មន្ទីរពិសោធន៍ នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានផ្តល់លទ្ធផលនៃការធ្វើកោសលវិច័យគ្រឿងញៀន ដែលមានចំនួន ០៣សំណាក៖

- **សំណាកទី១** ជាគ្រឿងញៀនប្រភេទក្រាមម្សៅឈ្មោះ **កេតាមីន** ស្ថិតក្នុងតារាងទី៣ មាត្រា ៥ ដែលមានបរិមាណភាពសុទ្ធ ៦៦,៧៦ ភាគរយ នៃទម្ងន់សរុប ដូច្នេះគ្រឿងញៀនដែលបានដកហូតមានទម្ងន់សរុប ២០,៣០ក្រាម ត្រូវមានបរិមាណភាពសុទ្ធសរុបស្មើនឹង (២០,៣០ x ៦៦,៧៦/១០០)= ១៣,៥៥ក្រាម (ទម្ងន់សុទ្ធ) ។ សកម្មភាពល្មើសទាក់ទងនឹងសារធាតុញៀន ដែលមានបរិមាណសុទ្ធក្នុងកំរិតនេះ មិនត្រូវបានចែងជាពិសេសទេ ដូច្នេះមានន័យថា មានកំណត់នៅក្នុងផ្នែកទូទៅនៃមាត្រា ៤៨ **កថាខណ្ឌ២** នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។
- **សំណាកទី២** ជាគ្រឿងញៀនប្រភេទក្រាមម្សៅឈ្មោះ **មេតំហ្វេមីន** (ហៅក្រៅអាយ ឬ ម៉ាទឹកកក) ស្ថិតក្នុងតារាងទី២ មាត្រា៥ ដែលមានបរិមាណភាពសុទ្ធ ៧៩,២២ ភាគរយ នៃទម្ងន់សរុប ដូច្នេះគ្រឿងញៀនដែលបានដកហូតមានទម្ងន់សរុប ១២,៨៣ក្រាម ត្រូវមានបរិមាណភាពសុទ្ធសរុបស្មើនឹង (១២,៨៣ x ៧៩,២២/១០០)= ១០,១៦ក្រាម (ទម្ងន់សុទ្ធ) ។ សកម្មភាពល្មើសទាក់ទងនឹងសារធាតុញៀន ដែលមានបរិមាណសុទ្ធក្នុងកំរិតនេះ មិនត្រូវបានចែងជាពិសេសទេ ដូច្នេះមានន័យថា មានកំណត់នៅក្នុងផ្នែកទូទៅនៃមាត្រា ៤០ កថាខណ្ឌ២ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

---

4 លិខិតលេខ ២១៥៧២/១៩ ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៩ របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។ (ឯកសារលេខ ១៩/៣)

- *សំណាកទី៣ ជាគ្រឿងញៀនប្រភេទគ្រាប់ឈ្មោះ* **មេតំហ្វេមីន (ហៅក្រៅយ៉ាបា ឬ ថ្នាំឆ្កួត)** *ស្ថិតក្នុងតារាងទី២ មាត្រា៩ ដែលមានបរិមាណភាពសុទ្ធ ១៧,៣៩ ភាគរយ នៃទម្ងន់សរុប ដូច្នេះគ្រឿងញៀនដែលបានដកហូតមានទម្ងន់សរុប ០,៩៨ក្រាម ត្រូវមានបរិមាណភាពសុទ្ធសរុបស្មើនឹង (០,៩៨ x ១៧,៣៩/១០០)= ០,១៧ក្រាម (ទម្ងន់សុទ្ធ) ។ សកម្មភាពល្មើសទាក់ទងនឹងសារធាតុញៀនដែលមានបរិមាណសុទ្ធក្នុងកំរិតនេះ មិនត្រូវបានចែងជាពិសេសទេ ដូច្នេះមានន័យថា មានកំណត់នៅក្នុងផ្នែកទូទៅនៃមាត្រា ៤០* **កថាខណ្ឌ២** *នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។*

៣.៩ *យោងតាមសំអាងហេតុខាងលើ ពិតជាបង្ហាញឱ្យឃើញពីពិរុទ្ធភាពលើជនជាប់ចោទឈ្មោះ* [redacted] HAO *ពីបទ* **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** *ប្រព្រឹត្តនៅចំណុចភូមិ៣ សង្កាត់លេខ២ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០* **កថាខណ្ឌ២** *និងមាត្រា ៤៨* **កថាខណ្ឌ២** *នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន*[5] ។

៣.១០ *កំរិតនៃទណ្ឌកម្មដែលមានកំណត់ក្នុងមាត្រា ៤០* **កថាខណ្ឌ២** *និងមាត្រា ៤៨* **កថាខណ្ឌ២** *នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន មានកំរិតចាប់ពី ០២ឆ្នាំ រហូតដល់ ០៥ឆ្នាំ និងពិន័យជាប្រាក់ចាប់ពី* **៤.០០០.០០០ (បួនលាន) រៀល** *រហូតដល់* **១០.០០០.០០០ (ដប់លាន) រៀល** *ដូច្នេះតុលាការពិចារណាអំពីការប្រកាសទោសក្នុងកំរិតដែលមានកំណត់នេះ*[6] *ដោយពិចារណាផ្អែកលើចរិកលក្ខណៈនៃអំពើដែលរងការចោទប្រកាន់ រួមជាមួយនឹងកាលៈទេសៈបទល្មើស និងបុគ្គលិកលក្ខណៈនៃជនជាប់ចោទផងដែរ ។*

៣.១១ *តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋាន សូមធ្វើការតម្កល់ការចោទប្រកាន់ទុកជាបានការដដែល ។ តប្បីតុលាការលើកយកមកពិចារណា ។*

៣.១២ *មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋាន សូមឱ្យតុលាការជួយសម្រាលទោសឱ្យកូនក្តីខ្លួនផង ដោយយោងតាមមាត្រា ៩៣ នៃក្រមព្រហ្មទណ្ឌ ។ តប្បីតុលាការលើកយកមកពិចារណា ។*

៣.១៣ *ជនជាប់ចោទបាននិយាយសំដីចុងក្រោយថា សូមឱ្យតុលាការមេត្តាបន្ធូរបន្ថយទោសឱ្យខ្លួនផង ។ តប្បីតុលាការលើកយកមកពិចារណា ។*

---

[5] *មាត្រាពាក់ព័ន្ធ មាត្រា៤០* **កថាខណ្ឌ២** *និងមាត្រា ៤៨* **កថាខណ្ឌ២** *នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។*

[6] **ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០១២៖** *ត្រង់មាត្រា៤០ កថាខ័ណ្ឌ២ និងមាត្រា ៤៨ កថាខណ្ឌ២ ។*



Scanned with CamScanner

៣.១៤ វត្ថុតាងរួមមាន: ម្សៅសថ្នាំចំនួន១៦,៨៣ក្រាម, ម្សៅសថ្នាំលាយក្រហម-លឿង ចំនួន២០,៣០ក្រាម, ថ្នាំគ្រាប់ពណ៌ក្រហមចំនួន ១០គ្រាប់ មានទម្ងន់០,៩៨ក្រាម, ជញ្ជីងចំនួន០១ និងទូរស័ព្ទដៃចំនួន០២គ្រឿង ។ គប្បីតុលាការធ្វើការរឹបអូស និង បំផ្លាញចោល ។

## ៤.ផ្នែកសេចក្តីសម្រេច៖
## ហេតុដូច្នេះសាលាដំបូងខេត្តព្រះសីហនុ
## វិនិច្ឆ័យសេចក្តី

**៤.១** ផ្តន្ទាទោសលើឈ្មោះ [redacted] HAO ភេទប្រុស អាយុ ៣៣ឆ្នាំ ជនជាតិចិន (មានសាវតារជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល **៣(បី)ឆ្នាំ** និងពិន័យជាប្រាក់ចំនួន **៤.000.000 (បួនលាន) រៀល** ។

ពីបទ: ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌ២ និងមាត្រា ២៨ កថាខណ្ឌ ២ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រព្រឹត្តនៅចំណុចភូមិ៣ សង្កាត់លេខ ២ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៩ ។

**៤.២** ហាមឃាត់ដល់ជនជាប់ចោទឈ្មោះ [redacted] HAO ភេទប្រុស (មានសាវតារជាតិដូចខាងលើ) ក្នុងការស្នាក់នៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងរយៈពេល ០៥ (ប្រាំ) ឆ្នាំ គិតចាប់ពីពេលដែលជនជាប់ចោទរូបនេះបានអនុវត្តទណ្ឌកម្មខាងពន្ធនាគាររួច តាមបញ្ញត្តិមាត្រា ៦១ នៃក្រមព្រហ្មទណ្ឌ ។

**៤.៣** វត្ថុតាងរួមមាន៖

- ម្សៅសថ្នាំចំនួន១៦,៨៣ក្រាម
- ម្សៅសថ្នាំលាយក្រហម,លឿងចំនួន២០,៣០ក្រាម
- ថ្នាំគ្រាប់ពណ៌ក្រហមចំនួន១០គ្រាប់ មានទម្ងន់០,៩៨ក្រាម
- ជញ្ជីងចំនួន០១
- ទូរស័ព្ទដៃចំនួន០២គ្រឿង

ត្រូវរឹបអូស និងបំផ្លាញចោល ។

សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២០ និងប្រកាសជាសាធារណៈនៅថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២០ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] HAO ។ ទុកសិទ្ធិឱ្យប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

**ក្រឡាបញ្ជី** | **ចៅក្រមជំនុំជម្រះ**

[redacted] | [redacted]



Scanned with CamScanner